ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តបាត់ដំបង**
សំណុំរឿងរដ្ឋប្បវេណីលេខ ៤៧
ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០២៣
សាលក្រមលេខ ១២៦ (ខ)
ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២៣

## តាមនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តបាត់ដំបង

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៣

**ចៅក្រមជំនុំជម្រះ**

លោក [redacted] អនុប្រធានសាលាដំបូងខេត្តបាត់ដំបង

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជី នៃសាលាដំបូងខេត្តបាត់ដំបង

**-ដើមចោទ៖** [redacted] មានអាសយដ្ឋានអគារលេខ១៣ ផ្លូវ [redacted] មានតំណាងស្របច្បាប់ដោយ **ឯកឧត្តមបណ្ឌិត** [redacted] ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក ។

**អ្នកតំណាងដោយអាណត្តិ៖** មេធាវី [redacted] និង មេធាវី [redacted] មានការិយាល័យស្ថិតនៅ [redacted] ។

**-ចុងចម្លើយ៖** [redacted] មានអាសយដ្ឋាននៅផ្ទះលេខ [redacted] មានតំណាងស្របច្បាប់ដោយលោក [redacted] **ប៊ុនណាត** ភេទប្រុស កើតថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៨៣ ជនជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ លេខ ១៧១០៣៤២៨៥ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៦ មានអាសយដ្ឋានបច្ចុប្បន្ននៅ [redacted] ។

**អង្គហេតុ និងចំណុចវិវាទ**

**១. ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ**

ក-ប្រកាសថាគ្រឹះស្ថាន [redacted] តំណាងស្របច្បាប់ដោយឈ្មោះ [redacted] ប៊ុនណាត មាន កំហុសមិនបានបំពេញកាតព្វកិច្ច តាមកិច្ចព្រមព្រៀងខ្ចីចងការប្រាក់ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៨ ។

ខ-បង្គាប់ឱ្យគ្រឹះស្ថាន [redacted] តំណាងស្របច្បាប់ដោយឈ្មោះ [redacted] ប៊ុនណាត ភេទប្រុស អាយុ៣៦ឆ្នាំ មានអាសយដ្ឋាន [redacted] សងប្រាក់ដើមចំនួន ៣២៥.០០០ (បីរយម្ភៃប្រាំពាន់) ដុល្លារអាមេរិក មកឱ្យដើមចោទតាមកិច្ចព្រមព្រៀងខ្ចីចងការប្រាក់ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៨ ។



Scanned with CamScanner

គ-បង្គាប់ឱ្យគ្រឹះស្ថាន [redacted] តំណាងស្របច្បាប់ដោយឈ្មោះ [redacted] ប៊ុនណាត ភេទប្រុស អាយុ៣៦ឆ្នាំ មានអាសយដ្ឋាន [redacted] សងការប្រាក់ ៨% ក្នុងមួយឆ្នាំ លើប្រាក់ដើមចំនួន ៣២៥.០០០ (បីរយម្ភៃប្រាំពាន់) ដុល្លារអាមេរិក មកឱ្យដើមចោទ គិតចាប់ពីថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៩ និងបូកបន្ថែមរហូតដល់ថ្ងៃសងប្រាក់ដើមគ្រប់ចំនួន ។

ឃ-បង្គាប់ឱ្យគ្រឹះស្ថាន [redacted] តំណាងស្របច្បាប់ដោយឈ្មោះ [redacted] ប៊ុនណាត ភេទប្រុស អាយុ៣៦ឆ្នាំ មានអាសយដ្ឋាន [redacted] សងប្រាក់ពិន័យតាមអត្រាការប្រាក់ ១៦% ក្នុងមួយឆ្នាំ លើប្រាក់ដើមចំនួន ៣២៥.០០០ (បីរយម្ភៃប្រាំពាន់) ដុល្លារអាមេរិក មកឱ្យដើមចោទ គិតចាប់ពីថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៩ និងបូកបន្ថែម រហូតដល់ថ្ងៃសងប្រាក់ដើមគ្រប់ចំនួន ។

ង-បង្គាប់ឱ្យគ្រឹះស្ថាន [redacted] តំណាងស្របច្បាប់ដោយឈ្មោះ [redacted] ប៊ុនណាត ភេទប្រុស អាយុ៣៦ឆ្នាំ មានអាសយដ្ឋាន [redacted] សងប្រាក់សោហ៊ុយទម្រង់ការដែលជំពាក់ចំនួន ១៣.០០០ (ដប់បីពាន់ ) ដុល្លារអាមេរិក មកឱ្យដើមចោទ គិតចាប់ពីថ្ងៃជំពាក់ និងបូកបន្ថែមរហូតដល់ថ្ងៃទូទាត់ជាក់ស្តែង ។

ច-បង្គាប់ឱ្យ គ្រឹះស្ថាន [redacted] តំណាងស្របច្បាប់ដោយឈ្មោះ [redacted] ប៊ុនណាត ភេទប្រុស អាយុ៣៦ឆ្នាំ មានអាសយដ្ឋាន [redacted] សងប្រាក់សោហ៊ុយសេវាផ្លូវច្បាប់ចំនួន ១៥.០០០ (ដប់ប្រាំពាន់) ដុល្លារអាមេរិក មកឱ្យដើមចោទ ។

ឆ-ប្រាក់ពន្ធ និងប្រាក់ប្រដាប់ក្តីតុលាការទាំងអស់ជាបន្ទុករបស់ចុងចម្លើយ ។

ជ-សុំឱ្យតុលាការប្រកាសថា សាលក្រមនេះមានអានុភាពអនុវត្តជាបណ្តោះអាសន្ន ។

**២. ដំណើររឿងក្តី និងចំណុចវិវាទ**

**ក. ការសង្ខេបអំពីរឿងក្តី**

កាលពីថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៨ ចុងចម្លើយបានចុះកិច្ចសន្យាខ្ចីបរិភោគជាមួយម្ចាស់បំណុល ក្នុងទឹកប្រាក់ចំនួន ២២៥.០០០ (ពីររយម្ភៃប្រាំពាន់) ដុល្លារអាមេរិក ដើម្បីផ្តល់ឥណទានបន្តដល់អតិថិជនរបស់អង្គការដៃគូសហគមន៍ (ត្រូវបានប្តូរនាមករណ៍ពី អង្គការដៃគូសហគមន៍ ទៅជា ប្រតិបត្តិករឥណទានជនបទ [redacted] ដោយកូនបំណុលយល់ព្រមបង់ការប្រាក់ ៨% ( ប្រាំបី) ភាគរយ ក្នុងមួយឆ្នាំ រយៈពេលខ្ចីចងការ ២៨ (ម្ភៃប្រាំបី) ខែ គិតចាប់ពីថ្ងៃ៣០ ខែធ្នូ ឆ្នាំ២០១៨ ដល់ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២១ សោហ៊ុយទម្រង់ការ ១% (មួយ) ភាគរយ ប្រចាំឆ្នាំ លើសមតុល្យឥណទាន គិតចាប់ពីថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៩ ។

នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៨ ចុងចម្លើយបានចុះកិច្ចសន្យាខ្ចីបរិភោគជាមួយម្ចាស់បំណុលមួយទៀតក្នុងទឹកប្រាក់ចំនួន ១០០.០០០ (មួយរយពាន់) ដុល្លារអាមេរិក ដើម្បីផ្តល់ឥណទានបន្តដល់អតិថិជនរបស់អង្គការដៃគូសហគមន៍ (ត្រូវបានប្តូរនាមករណ៍ពី អង្គការដៃគូសហគមន៍ ទៅជា ប្រតិបត្តិករឥណទានជនបទ [redacted] ដោយកូនបំណុលយល់ ព្រមបង់ការប្រាក់ ៨% (ប្រាំបី) ភាគរយ ក្នុងមួយឆ្នាំរយៈពេលខ្ចីចងការ ០៥ (ប្រាំ) ឆ្នាំ និងសោហ៊ុយទម្រង់ការ ១% (មួយ) ភាគរយ ប្រចាំឆ្នាំលើសមតុល្យឥណទាន ។

សរុបទាំងពីរលើក មានទឹកប្រាក់ដើមចំនួន ៣២៥.០០០.០០ (បីរយម្ភៃប្រាំពាន់) ដុល្លារអាមេរិក ។ នៅពេលចុះកិច្ចសន្យាខ្ចីនោះ ចុងចម្លើយបានយល់ព្រមដោយស្ម័គ្រចិត្តបង្កើតហ៊ីប៉ូតែកលើ វិញ្ញាបនបត្រ

សម្គាល់ម្ចាស់អចលនវត្ថុលេខ ០២១២០៦០២-០៩២០ វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០២១២០៦០២-០៦២៨ វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០២១២០៦០២-០៦៣០ វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០២១២០៦០២-០៩២១ វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០២១២០៦០២-០៦២៩ និងវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០២១២០៦០២-០៩១៩ ដើម្បីធានាបំណុល ។

ក្រោយពីបានចុះកិច្ចសន្យាខ្ចីបរិភោគទាំងពីរលើកនេះរួច ម្ចាស់បំណុលបានប្រគល់ប្រាក់ដើមចំនួន ៣២៥.០០០ (បីរយម្ភៃប្រាំពាន់) ដុល្លារអាមេរិក ឱ្យទៅកូនបំណុល ហើយកូនបំណុលក៏បានបង់ការប្រាក់ និងប្រាក់ ទម្រង់ការ ដូចដែលបានព្រមព្រៀងគ្នាជាមួយម្ចាស់បំណុល ។

ចាប់ពីថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៩ រហូតមកដល់បច្ចុប្បន្ន កូនបំណុលបានខកខានបង់ប្រាក់ដើម និងការប្រាក់ឱ្យម្ចាស់បំណុល រហូតដល់បច្ចុប្បន្ន ទោះបីជាម្ចាស់បំណុលបានដាស់តឿនកូនបំណុលយ៉ាងណាក៏ដោយ ក៏កូនបំណុលនៅតែមិនព្រមបង់ប្រាក់ឱ្យទៅម្ចាស់បំណុលដែរ ។ តាមរយៈក្រុមហ៊ុនមេធាវី [redacted] តំណាងឲ្យម្ចាស់បំណុល បានចេញលិខិតជូនដំណឹងលេខ ០៧៧/២២ ខ.ជ ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២២ និងលិខិតជូនដំណឹងលើកចុងក្រោយលេខ ២០០/២២ ខជ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២២ ស្តីពីការអនុវត្តកាតព្វកិច្ចទូទាត់សងបំណុលជូនធនាគារ នូវ៖

-ប្រាក់ដើមមានចំនួន USD ៣២៥.០០០.០០(បីរយម្ភៃប្រាំពាន់) ដុល្លារអាមេរិក

-ការប្រាក់មានចំនួន USD ៩៨.៧៧២,២២ (កៅសិបប្រាំបីពាន់ប្រាំពីររយចិតសិបពីរ កៀសម្ភៃពីរ) ដុល្លារអាមេរិក គិតត្រឹមថ្ងៃទី១១ ខែមករា ឆ្នាំ២០២៣ ។

- ប្រាក់ពិន័យមានចំនួន USD ៩៨.៧៧២,២២ (កៅសិបប្រាំបីពាន់ប្រាំពីររយចិតសិបពី កៀសម្ភៃពីរ) ដុល្លារអាមេរិក គិតត្រឹមថ្ងៃទី១១ ខែមករា ឆ្នាំ២០២៣ ។

-ប្រាក់ទម្រង់ការមានចំនួន ១៣.០០០,០០ (ដប់បីពាន់) ដុល្លារអាមេរិក គិតត្រឹមថ្ងៃទី១១ ខែមករា ឆ្នាំ២០២៣ ។

ដោយហេតុថាភាគីកូនបំណុលបានបំពានកាតព្វកិច្ចបង់ការប្រាក់តាមកិច្ចព្រមព្រៀងមកឱ្យភាគីម្ចាស់បំណុលជាច្រើនខែ ទើបភាគីម្ចាស់បំណុលបានធ្វើការដាស់តឿនជាច្រើនលើកច្រើនសារឱ្យកូនបំណុលធ្វើការសងប្រាក់ដើម និងការប្រាក់ តែភាគីកូនបំណុលនៅតែមិនអនុវត្តកាតព្វកិច្ចតាមកិច្ចសន្យា ដែលធ្វើឱ្យភាគីម្ចាស់បំណុលខាតបង់ផលប្រយោជន៍យ៉ាងធ្ងន់ធ្ងរ ។ ម្ចាស់បំណុលបានទាមទារឱ្យកូនបំណុលប្រមូលប្រាក់មកសងទាំងប្រាក់ដើម និងការប្រាក់ដែលជំពាក់មកម្ចាស់បំណុលវិញ ប៉ុន្តែកូនបំណុលនៅតែមិនសងប្រាក់ និងមិនទទួលខុសត្រូវចំពោះកាតព្វកិច្ចរបស់ខ្លួន ។

**ខ. ចំណុចវិវាទ ៖** គ្មាន ។

**គ. ការអះអាងរបស់ភាគី**

-មេធាវីតំណាងដោយអាណត្តិឲ្យដើមចោទ បានធ្វើសេចក្តីថ្លែងការណ៍ថា ដើមចោទសុំតម្កល់ការទាមទារ និងរក្សាការអះអាងអំពីអង្គហេតុដែលជាមូលហេតុចាំបាច់ដើម្បីបញ្ជាក់ការទាមទារ ដូចមាននៅក្នុងពាក្យបណ្តឹងចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០២៣ និងក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកទី១ និងលើកទី២ ដដែល ។



Scanned with CamScanner

តាមសេចក្តីថ្លែងការណ៍មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទបានធ្វើសេចក្តីថ្លែងការណ៍ថា កាលពីថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៨ ចុងចម្លើយឈ្មោះ [redacted] ប៊ុនណាត តំណាងស្របច្បាប់របស់ គ្រឹះស្ថាន [redacted] បានចុះកិច្ចសន្យាខ្ចីបរិភោគជាមួយម្ចាស់បំណុល ក្នុងទឹកប្រាក់ចំនួន ២២៥.០០០ (ពីររយម្ភៃប្រាំពាន់) ដុល្លារអាមេរិក ដើម្បីផ្តល់ឥណទានបន្តដល់អតិថិជនរបស់ អង្គការដៃគូសហគមន៍ (ត្រូវបានប្តូរនាមករណ៍ពី អង្គការដៃគូសហគមន៍ ទៅជា ប្រតិបត្តិករឥណទានជនបទ [redacted] ដោយកូនបំណុលយល់ព្រមបង់ការប្រាក់ ៨% ( ប្រាំបី) ភាគរយ ក្នុងមួយឆ្នាំ រយៈពេលខ្ចីចងការ ២៨ (ម្ភៃប្រាំបី) ខែ គិតចាប់ពីថ្ងៃ៣០ ខែធ្នូ ឆ្នាំ២០១៨ ដល់ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២១ សោហ៊ុយទម្រង់ការ ១% (មួយ) ភាគរយ ប្រចាំឆ្នាំ លើសមតុល្យឥណទាន គិតចាប់ពីថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៩ ។

នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៨ ចុងចម្លើយឈ្មោះ [redacted] ប៊ុនណាត តំណាងស្របច្បាប់របស់ គ្រឹះស្ថាន [redacted] ក៏បានចុះកិច្ចសន្យាខ្ចីបរិភោគជាមួយម្ចាស់បំណុលមួយទៀត ក្នុងទឹកប្រាក់ចំនួន ១០០.០០០ (មួយរយពាន់) ដុល្លារអាមេរិក ដើម្បីផ្តល់ឥណទានបន្តដល់អតិថិជនរបស់ អង្គការដៃគូសហគមន៍(ត្រូវបានប្តូរនាមករណ៍ពី អង្គការដៃគូសហគមន៍ ទៅជា ប្រតិបត្តិករឥណទានជនបទ [redacted] ដោយកូនបំណុលយល់ព្រមបង់ការប្រាក់ ៨% (ប្រាំបី) ភាគរយ ក្នុងមួយឆ្នាំរយៈពេលខ្ចីចងការ ០៥ (ប្រាំ) ឆ្នាំ និងសោហ៊ុយទម្រង់ការ ១% (មួយ) ភាគរយ ប្រចាំឆ្នាំលើសមតុល្យឥណទាន ។

សរុបទាំងពីរលើក មានទឹកប្រាក់ដើមចំនួន ៣២៥.០០០.០០ (បីរយម្ភៃប្រាំពាន់) ដុល្លារអាមេរិក ។ នៅពេលចុះកិច្ចសន្យាខ្ចីនោះ ចុងចម្លើយបានយល់ព្រមដោយស្ម័គ្រចិត្តបង្កើតហ៊ីប៉ូតែកលើ វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០២១២០៦០២-០៩២០ វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០២១២០៦០២-០៦២៨ វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០២១២០៦០២-០៦៣០ វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០២១២០៦០២-០៩២១ វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០២១២០៦០២-០៦២៩ និងវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០២១២០៦០២-០៩១៩ ដើម្បីធានាបំណុល ។

ក្រោយពីបានចុះកិច្ចសន្យាខ្ចីបរិភោគទាំងពីរលើកនេះរួច ម្ចាស់បំណុលបានប្រគល់ប្រាក់ដើមចំនួន ៣២៥.០០០ (បីរយម្ភៃប្រាំពាន់) ដុល្លារអាមេរិក ឱ្យទៅកូនបំណុល ហើយកូនបំណុលក៏បានបង់ការប្រាក់ និងប្រាក់ ទម្រង់ការ ដូចដែលបានព្រមព្រៀងគ្នាជាមួយម្ចាស់បំណុល ។

ចាប់ពីថ្ងៃ៣០ ខែមីនា ឆ្នាំ២០១៩ រហូតមកដល់បច្ចុប្បន្ន កូនបំណុលបានខកខានបង់ប្រាក់ដើម ការប្រាក់ឱ្យម្ចាស់បំណុល រហូតដល់បច្ចុប្បន្ន ទោះបីជាម្ចាស់បំណុលបានដាស់តឿនកូនបំណុលយ៉ាងណាក៏ដោយ ក៏កូនបំណុលនៅតែមិនព្រមបង់ប្រាក់ឱ្យទៅម្ចាស់បំណុលដែរ ។ ម្ចាស់បំណុលតាមរយៈក្រុមហ៊ុន [redacted] បានចេញលិខិតជូនដំណឹងលេខ ០៧៧/២២ ខ.ជ ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២២ និងលិខិតជូនដំណឹងលើកចុងក្រោយ លេខ ២០០/២២ ខជ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២២ ស្តីពីការអនុវត្តកាតព្វកិច្ចទូទាត់សងបំណុលជូនធនាគារ ។

ជាសរុបមាន :

-ប្រាក់ដើមមានចំនួន USD ៣២៥.០០០.០០ (បីរយម្ភៃប្រាំពាន់) ដុល្លារអាមេរិក ។

-ការប្រាក់មានចំនួន USD ៩៨.៧៧២,២២ (កៅសិបប្រាំបីពាន់ប្រាំពីររយចិតសិបពីរ សេន្តម្ភៃពីរ) ដុល្លារអាមេរិក គិតត្រឹមថ្ងៃទី១១ ខែមករា ឆ្នាំ២០២៣ ។



Scanned with CamScanner

-ប្រាក់ពិន័យមានចំនួន USD ៩៨.៧៧២,២២ (កៅសិបប្រាំបីពាន់ប្រាំពីររយចិតសិបពី ក្បៀសម្ភៃពីរ) ដុល្លារអាមេរិក គិតត្រឹមថ្ងៃទី១១ ខែមករា ឆ្នាំ២០២៣ ។

-ប្រាក់ទម្រង់ការមានចំនួន ១៣.០០០,០០ (ដប់បីពាន់) ដុល្លារអាមេរិក គិតត្រឹមថ្ងៃទី១១ ខែមករា ឆ្នាំ២០២៣ ។

ដោយហេតុថា ភាគីកូនបំណុលឈ្មោះ [redacted] ប៊ុនណាត តំណាងស្របច្បាប់របស់ គ្រឹះស្ថាន [redacted] នៃន ម.ក បានបំពានកាតព្វកិច្ចបង់ការប្រាក់តាមកិច្ចព្រមព្រៀងមកឱ្យភាគីម្ចាស់បំណុលជាច្រើនខែ ។ ភាគីម្ចាស់បំណុលបានធ្វើការដាស់តឿនជាច្រើនលើកច្រើនសារឱ្យកូនបំណុលធ្វើការសងប្រាក់ដើម និងការប្រាក់ តែភាគីកូន បំណុលនៅតែមិនអនុវត្តកាតព្វកិច្ចតាមកិច្ចសន្យា ដែលធ្វើឱ្យភាគីម្ចាស់បំណុលខាតបង់ផលប្រយោជន៍យ៉ាងធ្ងន់ធ្ងរ ។ ម្ចាស់បំណុលបានទាមទារឱ្យកូនបំណុលប្រមូលប្រាក់មកសងទាំងប្រាក់ដើម និងការប្រាក់ដែលជំពាក់មកម្ចាស់បំណុលវិញ ប៉ុន្តែកូនបំណុលនៅតែមិនសងប្រាក់ និងមិនទទួលខុសត្រូវចំពោះកាតព្វកិច្ចរបស់ខ្លួន ។

-ចុងចម្លើយ អវត្តមាន ។

**ឃ. ឯកសារភស្តុតាង (ថតចម្លង)**

-កិច្ចសន្យាខ្ចីបរិភោគលេខ ២១៣-០១/១៦-០៥ LA ធ.អ.ជ / RDB ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៨

-កិច្ចសន្យាខ្ចីបរិភោគលេខ ២១៣-០១/១៨-០៥ LA ធ.អ.ជ / RDB ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៨

-កិច្ចសន្យាបង្កើតហ៊ីប៉ូតែករួមលេខ ២១៣-៤៤/១៩-០៥MA ធអជ /RDB ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៩

-កិច្ចសន្យាបង្កើតហ៊ីប៉ូតែករួមលេខ ២១៣-៤៣/១៩-០៥MA ធ. អ. ជ/RDB ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៩

-ឧបសម្ព័ន្ធទី ១ និង ឧបសម្ព័ន្ធទី ២ នៃកិច្ចស្យា ។

## សំអាងហេតុ

**ក-ការវិនិច្ឆ័យចំពោះការទាមទារ**

១-តាមកិច្ចសន្យាខ្ចីបរិភោគលេខ ២១៣-០១/១៦-០៥ LA ធ.អ.ជ / RDB ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៨ រវាង [redacted] និងគ្រឹះស្ថាន [redacted] ឃើញថាចុងចម្លើយបានខ្ចីប្រាក់ពីដើមចោទចំនួន ២២៥.០០០ (ពីររយម្ភៃប្រាំពាន់) ដុល្លារអាមេរិក ក្នុងអត្រាការប្រាក់ ៨% (ប្រាំបីភាគរយ) ក្នុងមួយឆ្នាំ ដោយមានរយៈពេលខ្ចីចងការចំនួន ២៨ ខែ គិតចាប់ពីថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៨ ដល់ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២១ ។

២-តាមកិច្ចសន្យាខ្ចីបរិភោគលេខ ២១៣-០១/១៦-០៥ LA ធ.អ.ជ / RDB ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៨ រវាង [redacted] ឃើញថាចុងចម្លើយបានខ្ចីប្រាក់ពីដើមចោទចំនួន ១០០.០០០ (មួយរយពាន់) ដុល្លារអាមេរិក ក្នុងអត្រាការប្រាក់ ៨% (ប្រាំបីភាគរយ) ក្នុងមួយឆ្នាំ ដោយមានរយៈខ្ចីចំនួន ០៥ឆ្នាំ គិតចាប់ពី ថ្ងៃ ខែ ឆ្នាំ ដែលបានដកប្រាក់កម្ចីដោយផ្អែកលើតារាងបំណុលខាលើកិច្ចសន្យាខ្ចីបរិភោគ ។

៣-តាមសេចក្តីថ្លែងការណ៍របស់មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទបានរៀបរាប់ថា កាលពីថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៨ ចុងចម្លើយឈ្មោះ [redacted] ប៊ុនណាត តំណាងស្របច្បាប់របស់ [redacted]



Scanned with CamScanner

[redacted]បានចុះកិច្ចសន្យាខ្ចីបរិភោគជាមួយម្ចាស់បំណុល ក្នុងទឹកប្រាក់ចំនួន ២២៥.០០០ (ពីររយម្ភៃប្រាំពាន់) ដុល្លារអាមេរិក ដើម្បីផ្តល់ឥណទានបន្តដល់អតិថិជនរបស់ អង្គការដៃគូសហគមន៍ (ត្រូវបានប្តូរនាមករណ៍ពី អង្គការដៃគូសហគមន៍ ទៅជា ប្រតិបត្តិករឥណទានជនបទ [redacted] ដោយកូនបំ ណុល យល់ព្រមបង់ការប្រាក់ ៨% ( ប្រាំបី) ភាគរយ ក្នុងមួយឆ្នាំ រយៈពេលខ្ចីចងការ ២៨(ម្ភៃប្រាំបី)ខែ គិត ចាប់ពី ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៨ ដល់ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២១ សោហ៊ុយទម្រង់ការ ១% (មួយ) ភាគរយ ប្រចាំ ឆ្នាំ លើសមតុល្យឥណទាន គិតចាប់ពីថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៩ ។ នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៨ ចុង ចម្លើយឈ្មោះ[redacted]ប៊ុនណាត តំណាងស្របច្បាប់របស់ [redacted]ក៏បានចុះកិច្ច សន្យា ខ្ចីបរិភោគជាមួយម្ចាស់បំណុលមួយទៀត ក្នុងទឹកប្រាក់ចំនួន ១០០.០០០ (មួយរយពាន់) ដុល្លារអាមេរិក ដើម្បីផ្តល់ឥណទានបន្តដល់អតិថិជនរបស់ អង្គការដៃគូសហគមន៍(ត្រូវបានប្តូរនាមករ ណ៍ពី អង្គការដៃគូស ហគមន៍ ទៅជា ប្រតិបត្តិករឥណទានជនបទ[redacted]) ដោយកូនបំណុលយល់ ព្រមបង់ការ ប្រាក់ ៨% (ប្រាំបី) ភាគរយ ក្នុងមួយឆ្នាំរយៈពេលខ្ចីចងការ ០៥ (ប្រាំ) ឆ្នាំ និងសោហ៊ុយទម្រង់ការ ១% (មួយ) ភាគរយ ប្រចាំឆ្នាំលើសមតុល្យឥណទាន ។ សរុបទាំងពីរ មានទឹកប្រាក់ដើមចំនួន ៣២៥,០០០.០០ (បីរយម្ភៃប្រាំពាន់) ដុល្លារអាមេរិក ។ នៅពេលចុះកិច្ចសន្យាខ្ចីនោះ ចុងចម្លើយបានយល់ព្រមដោយស្ម័គ្រចិត្ត បង្កើតហ៊ីប៉ូតែកលើ វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០២១២០៦០២-០៩២០ វិញ្ញាបនបត្រ សម្គាល់ម្ចាស់អចលនវត្ថុលេខ ០២១២០៦០២-០៦២៨ វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០២១ ២០៦០២-០៦៣០ វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០២១២០៦០២-០៩២១ វិញ្ញាបនបត្រ សម្គាល់ម្ចាស់អចលនវត្ថុលេខ ០២១២០៦០២-០៦២៩ និងវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០២១២០៦០២-០៩១៩ ដើម្បីធានាបំណុល ។ ក្រោយពីបានចុះកិច្ចសន្យាខ្ចីបរិភោគទាំងពីរលើកនេះរួច ម្ចាស់បំណុលបានប្រគល់ប្រាក់ដើមចំនួន ៣២៥.០០០ (បីរយម្ភៃប្រាំពាន់) ដុល្លារអាមេរិក ឱ្យទៅកូនបំណុល ហើយកូនបំណុលក៏បានបង់ការប្រាក់ និងប្រាក់ ទម្រង់ការ ដូចដែលបានព្រមព្រៀងគ្នាជាមួយម្ចាស់បំណុល ។ ចាប់ពីថ្ងៃ៣០ ខែមីនា ឆ្នាំ២០១៩ រហូតមកដល់បច្ចុប្បន្ន កូនបំណុលបានខកខានបង់ប្រាក់ដើម ការ ប្រាក់ឱ្យម្ចាស់បំណុល រហូតដល់បច្ចុប្បន្ន ទោះបីជាម្ចាស់បំណុលបានដាស់តឿនកូនបំណុលយ៉ាងណាក៏ ដោយ ក៏កូនបំណុលនៅតែមិនព្រមបង់ប្រាក់ឱ្យទៅម្ចាស់បំណុលដែរ ។ ម្ចាស់បំណុលតាមរយៈក្រុមហ៊ុន មេធាវីខេមជីន បានចេញលិខិតជូនដំណឹងលេខ ០៧៧/២២ ខ.ជ ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២២ និង លិខិតជូនដំណឹងលើកចុងក្រោយលេខ ២០០/២២ ខជ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២២ ស្តីពីការអនុវត្ត ភាតព្វកិច្ចទូទាត់សងបំណុលជូនធនាគារ ។ ជាសរុបមាន៖

-ប្រាក់ដើមមានចំនួន USD ៣២៥.០០០.០០ (បីរយម្ភៃប្រាំពាន់) ដុល្លារអាមេរិក ។

-ការប្រាក់មានចំនួន USD ៩៨.៧៧២,២២ (កៅសិបប្រាំបីពាន់ប្រាំពីររយចិតសិបពីរ កៀសម្ភៃពីរ) ដុល្លារអាមេរិក គិតត្រឹមថ្ងៃទី១១ ខែមករា ឆ្នាំ២០២៣ ។

-ប្រាក់ពិន័យមានចំនួន USD ៩៨.៧៧២,២២ (កៅសិបប្រាំបីពាន់ប្រាំពីររយចិតសិបពីរ កៀសម្ភៃពីរ) ដុល្លារអាមេរិក គិតត្រឹមថ្ងៃទី១១ ខែមករា ឆ្នាំ២០២៣ ។

-ប្រាក់ទម្រង់ការមានចំនួន ១៣.០០០,០០ (ដប់បីពាន់) ដុល្លារអាមេរិក គិតត្រឹមថ្ងៃទី១១ ខែមករា ឆ្នាំ ២០២៣ ។



Scanned with CamScanner

ដោយហេតុថា ភាគីកូនបំណុលឈ្មោះ [redacted] ប៊ុនណាត តំណាងស្របច្បាប់របស់ គ្រឹះស្ថាន [redacted] បានបំពានកាតព្វកិច្ចបង់ការប្រាក់តាមកិច្ចព្រមព្រៀងមកឱ្យភាគីម្ចាស់បំណុលជាច្រើនខែ ។ ភាគីម្ចាស់បំណុលបានធ្វើការដាស់តឿនជាច្រើនលើកច្រើនសារឱ្យកូនបំណុលធ្វើការសងប្រាក់ដើម និងការប្រាក់ តែភាគីកូន បំណុលនៅតែមិនអនុវត្តកាតព្វកិច្ចតាមកិច្ចសន្យា ដែលធ្វើឱ្យភាគីម្ចាស់បំណុលខាតបង់ផលប្រយោជន៍យ៉ាងធ្ងន់ធ្ងរ ។ ម្ចាស់បំណុលបានទាមទារឱ្យកូនបំណុលប្រមូលប្រាក់មកសងទាំងប្រាក់ដើម និងការប្រាក់ដែលជំពាក់មកម្ចាស់បំណុលវិញ ប៉ុន្តែកូនបំណុលនៅតែមិនសងប្រាក់ និងមិនទទួលខុសត្រូវចំពោះកាតព្វកិច្ចរបស់ខ្លួន ។

៤-ចុងចម្លើយមិនបានបង្ហាញខ្លួននៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ឡើយ ដូច្នេះតុលាការត្រូវចាត់ទុកថាចុងចម្លើយបានសារភាពតាមសេចក្តីថ្លែងការណ៍ របស់ដើមចោទដែលទាក់ទងនឹងអង្គហេតុដែលដើមចោទបានលើកឡើង ដោយអនុលោមតាមបញ្ញត្តិមាត្រា ២០១ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

៥-ផ្អែកតាមកិច្ចសន្យាខ្ចីបរិភោគលេខ: ២១៣-០១/១៦-០៥ LA ធ.អ.ជ / RDB ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៨ កិច្ចសន្យាខ្ចីបរិភោគលេខ: ២១៣-០១/១៨-០៥ LA ធ.អ.ជ / RDB ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៨ និងសេចក្តីថ្លែងការណ៍របស់ដើមចោទ ព្រមទាំងភស្តុតាងជាឯកសារមួយចំនួនទៀតនៅក្នុងសំណុំរឿង តុលាការយល់ឃើញថា ការទាមទាររបស់ដើមចោទត្រង់ចំណុច ខ គ ឃ ង គឺត្រឹមត្រូវ គប្បីតុលាការទទួលស្គាល់នូវការទាមទាររបស់ដើមចោទ ។

៦-ចំពោះការទាមទាររបស់ដើមចោទអំពីប្រាក់សោហ៊ុយសេវាផ្លូវច្បាប់ចំនួន ១៥.០០០ (ដប់ប្រាំពាន់) ដុល្លារអាមេរិក នោះ គប្បីតុលាការពិចារណាឲ្យបានសមហេតុផល ដោយគិតពិចារណាអំពីកាលៈទេសៈជុំវិញផ្សេងៗទៅលើទំហំនៃការខាតបង់ផលប្រយោជន៍ជាក់ស្តែងរបស់ដើមចោទ ដោយយោងតាមបញ្ញត្តិមាត្រា ៣៩៨ និងមាត្រា ៤០០ នៃក្រមរដ្ឋប្បវេណី ។

៧-ចំពោះការទាមទាររបស់ដើមចោទត្រង់ចំណុច ក អំពីការប្រកាសថាគ្រឹះស្ថាន [redacted] ម.ក តំណាងស្របច្បាប់ដោយឈ្មោះ [redacted] ប៊ុនណាត មានកំហុសមិនបានបំពេញកាតព្វកិច្ច តាមកិច្ចព្រមព្រៀងខ្ចីចងការប្រាក់ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៨ គឺជាការទាមទារដែលពុំមានផលប្រយោជន៍ ដោយពុំអាចអនុវត្តដោយបង្ខំបានឡើយ ដូច្នេះគប្បីតុលាការសម្រេចច្រានចោលការទាមទារ ។

៨-ចុងចម្លើយមិនបានបង្ហាញខ្លួននៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ទេ ប៉ុន្តែតុលាការបានធ្វើការបញ្ជូនដីកាកោះហៅ និងឯកសារផ្សេងៗដែលត្រូវបញ្ជូនទៅចុងចម្លើយ តាមការផ្សាយជាសាធារណៈត្រឹមត្រូវតាមច្បាប់ហើយ ។ ដោយគ្មានករណីណាមួយដូចមានចែងនៅក្នុងមាត្រា ២០២ នៃក្រមនីតិវិធីរដ្ឋប្បវេណីត្រូវបានតុលាការរកឃើញឡើយ ដូច្នេះតុលាការអាចចេញសាលក្រមកំបាំងមុខចុងចម្លើយបានដោយអនុលោមតាមបញ្ញត្តិមាត្រា ២០១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

**ខ-ស្តីពីការប្រកាសឲ្យអនុវត្តជាបណ្តោះអាសន្ន**

ចំពោះការទាមទាររបស់ដើមចោទអំពីប្រាក់ដើម គឺជាការទាមទារឲ្យផ្តល់ការការបើកជាប្រភេទសិទ្ធិលើបំណុលដែលមានគោលបំណងឲ្យសងជាប្រាក់ ដូច្នេះគប្បីតុលាការទទួលស្គាល់នូវការស្នើសុំអនុវត្តសាលក្រមជាបណ្តោះអាសន្នបាន ដោយអនុលោមតាមបញ្ញត្តិមាត្រា ១៩៦ កថាខណ្ឌទី១ និងទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។



Scanned with CamScanner

**<u>គ-ស្តីពីបន្ទុកនៃប្រាក់ប្រដាប់ក្តី</u>**

ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ភាគីចុងចម្លើយជាអ្នកចាញ់ក្តី យោងតាមបញ្ញត្តិមាត្រា ៦៤ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

## <u>សេចក្តីសម្រេចបញ្ចប់</u>

១-បង្គាប់ឲ្យចុងចម្លើយ **គ្រឹះស្ថាន** [redacted] តំណាងស្របច្បាប់ដោយឈ្មោះ [redacted] សងប្រាក់ទៅដើមចោទ [redacted] ដូចខាងក្រោម៖

ក-ប្រាក់ដើមចំនួន ៣២៥.០០០ (បីរយម្ភៃប្រាំពាន់) ដុល្លារអាមេរិក ។

ខ-ការប្រាក់ចំនួន ៨% (ប្រាំបីភាគរយ) ក្នុងមួយឆ្នាំ លើប្រាក់ដើមចំនួន ៣២៥.០០០ (បីរយម្ភៃប្រាំពាន់) ដុល្លារអាមេរិក គិតចាប់ពីថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៩ និងបូកបន្ថែមរហូតដល់ថ្ងៃសងប្រាក់ដើម គ្រប់ចំនួន ។

គ-ប្រាក់ពិន័យតាមអត្រាការប្រាក់ ១៦% (ដប់ប្រាំមួយភាគរយ) ក្នុងមួយឆ្នាំ លើប្រាក់ដើមចំនួន ៣២៥.០០០ (បីរយម្ភៃប្រាំពាន់) ដុល្លារអាមេរិក គិតចាប់ពីថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៩ និងបូកបន្ថែមរហូតដល់ថ្ងៃសងប្រាក់ដើមគ្រប់ចំនួន ។

ឃ-ប្រាក់សោហ៊ុយទម្រង់ការដែលជំពាក់ចំនួន ១៣.០០០ (ដប់បីពាន់) ដុល្លារអាមេរិក គិតចាប់ពីថ្ងៃជំពាក់ និងបូកបន្ថែមរហូតដល់ថ្ងៃទូទាត់ជាក់ស្តែង ។

ង-ប្រាក់សោហ៊ុយសេវាផ្លូវច្បាប់ចំនួន ១០.០០០ (មួយម៉ឺន) ដុល្លារអាមេរិក ។

២-ច្រានចោលការទាមទាររបស់ដើមចោទត្រង់ចំណុច ក ។

៣-សាលក្រមនេះអាចអនុវត្តជាបណ្តោះអាសន្នបានត្រង់ចំណុចទី ១ (ក) នៃសេចក្តីសម្រេចបញ្ចប់ ។

៤-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ ។

សាលក្រមនេះបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៣ និងប្រកាសជាសាធារណៈនៅថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២៣ កំបាំងមុខចុងចម្លើយ ។

**ចៅក្រម**

**ហត្ថលេខា និងត្រា** [redacted]

---

**បានចម្លងត្រឹមត្រូវតាមច្បាប់ដើម**

ថ្ងៃអង្គារ ១៣កើត ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៦

ធ្វើនៅបាត់ដំបង ថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២៣

**បានឃើញ**

**ចៅក្រម**

[redacted]

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner